ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៦ អយក. សណន

# សេចក្តីណែនាំ
# ស្តីពី
# ការបង្រៀន និងរៀនតាមបណ្តុំ
# សម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន នៅភូមិសាស្រ្ត ដែលមានហានិភ័យទាប

ក្នុងអំឡុងពេលនៃការផ្អាកដំណើរការគ្រឹះស្ថានសិក្សា ដោយសារព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ២០២១ គ្រឹះស្ថានសិក្សាបានដំណើរការការបង្រៀន និងរៀនពីចម្ងាយតាមគ្រប់រូបភាព ក្នុងនោះក៏មានការបង្រៀននិងរៀនតាមបណ្តុំ ដែលជាការមករៀនជុំគ្នាក្នុងទ្រង់ទ្រាយតូច រវាងគ្រូបង្រៀន និងសិស្ស នៅទីកន្លែងដែលមានសុវត្ថិភាព។ ដើម្បីធានាបាននូវការបន្តការសិក្សារបស់សិស្សានុសិស្ស និស្សិត ចាប់ពីខែកញ្ញា រហូតដល់ការបិទបញ្ចប់ឆ្នាំសិក្សា២០២០-២០២១ នៅខែវិច្ឆិកា ឆ្នាំ២០២១ និងដើម្បីរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិក្នុងខែវិច្ឆិកា និងមធ្យមសិក្សាទុតិយភូមិក្នុងខែធ្នូ ឆ្នាំ២០២១ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនអាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀននិងរៀនតាមបណ្តុំ អាស្រ័យលើស្ថានភាព ធនធាន និងការច្នៃប្រឌិតរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ នៅភូមិសាស្រ្ត ដែលធានាថាមិនមានការឆ្លងជំងឺកូវីដ-១៩ ជាពិសេសនៅតាមក្រុង-ស្រុក-ខណ្ឌដែលចាត់ទុកថាមានសុវត្ថិភាព នៅតាមខេត្តមួយចំនួន ឬយ៉ាងហោចណាស់ការរៀនជាបណ្តុំចំនួនតិចជាង១៥ នាក់នៅតាមថ្នាក់រៀន នៅតាមក្រុង-ស្រុក-ខណ្ឌ ដែលគ្មានការឆ្លងជំងឺកូវីដ-១៩។

យោងតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសូមធ្វើការណែនាំនូវគោលការណ៍សំខាន់ៗមួយចំនួនដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស ស្តីពីការបង្រៀននិងរៀនតាមបណ្តុំនៅតាមគ្រឹះស្ថានសិក្សា នៅភូមិសាស្រ្ត ដែលមានហានិភ័យទាប ដូចខាងក្រោម៖

**ទី១- ការបើកដំណើរការឡើងវិញគ្រឹះស្ថានសិក្សាចំណោះខុទៅគ្រប់កម្រិត នៅតាមក្រុង ស្រុក ខណ្ឌ ដែលមានហានិភ័យទាប ដោយអាជ្ញាធររាជធានី ខេត្ត ត្រូវធ្វើការវាយតម្លៃស្ថានភាពជាក់ស្តែង និងការអនុវត្តនូវគម្លាតសុវត្ថិភាព និងវិធានការសុខាភិបាលចាំបាច់នានា**

- គណៈអភិបាលរាជធានី ខេត្តត្រូវកំណត់ភូមិសាស្រ្តដែលមានហានិភ័យខ្ពស់ ភូមិសាស្រ្តដែលមានហានិភ័យទាប និងភូមិសាស្រ្តដែលពុំមានការឆ្លងជំងឺកូវីដ-១៩


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិភាក្សាជាមួយគណៈអភិបាលរាជធានី ខេត្ត ដើម្បីជ្រើសរើសសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលមានលទ្ធភាពបើកដំណើរការឡើងវិញ
- វាយតម្លៃ និងជ្រើសរើសគ្រឹះស្ថានសិក្សាដែលត្រូវបើកដំណើរការឡើងវិញ ដោយត្រូវរៀបចំយន្តការរៀននិងបង្រៀន និងត្រូវរៀបចំជាផែនការឱ្យបានច្បាស់លាស់ ដោយមានការអនុម័តពីអាជ្ញាធររាជធានី ខេត្ត រួចផ្ញើមកក្រសួង ដើម្បីបូកសរុប
- ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីមាតាបិតា បុគ្គលិកសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ព័ត៌មាន
- ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០។
- *ត្រូវបន្តអនុវត្តកម្មវិធីសិក្សាបង្រួម*
    - រៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ និងប្រចាំខែឡើងវិញ ដោយផ្តោតលើខ្លឹមសារមេរៀនសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការបន្តការសិក្សានៅថ្នាក់បន្តបន្ទាប់ទៀត
    - សង្ខេបខ្លឹមសារមេរៀនដោយផ្តោតលើបញ្ញត្តិ ដែលធ្វើឱ្យសិស្សងាយយល់ និងអាចយកទៅអនុវត្តបាន
    - លើកទឹកចិត្តសិស្សដែលមានលទ្ធភាពរៀនតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យចេះប្រើប្រាស់វីដេអូនៃការបង្រៀន និងសន្លឹកកិច្ចការ ដែលផលិតដោយនាយកដ្ឋានជំនាញនៃក្រសួង និងដែលមានចែកចាយក្នុងបណ្តាញតេឡេក្រាម វេបសាយ ឬកម្មវិធីទូរសព្ទដៃ
    - លើកទឹកចិត្តនិងជួយសិស្សឱ្យអនុវត្តលំហាត់ ឬធ្វើការហ្វឹកហាត់បន្ថែមនៅផ្ទះ
    - មុខវិជ្ជាផ្សេងទៀតត្រូវព្យួរសិនដោយនឹងត្រូវរៀនបំពេញបន្ថែមនៅដើមឆ្នាំសិក្សាបន្ទាប់

**ទី២- ការបន្តរៀនតាមបណ្តុំ ដែលមានចំនួនតិចជាង ១៥ នាក់ និងឆ្លាស់វេន ឬការរៀនតាមបែបចម្រុះចំពោះតំបន់ប្រជុំជន និងទីក្រុង ដែលមានការឆ្លងតិច និងមានការចាក់វ៉ាក់សាំងរួចហើយ**

- វាយតម្លៃតំបន់សិក្សា ដើម្បីរៀបចំយន្តការរៀននិងបង្រៀន និងត្រូវរៀបចំជាផែនការឱ្យបានច្បាស់លាស់ដោយមានការអនុម័តពីអាជ្ញាធររាជធានី ខេត្ត រួចផ្ញើមកក្រសួងដើម្បីបូកសរុប
- ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីមាតាបិតា និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ព័ត៌មាន

- ផ្តល់អាទិភាពទៅលើសិស្សថ្នាក់ទី៩ និងទី១២ ឱ្យរៀននៅតាមសាលារៀន ប៉ុន្តែក្នុងរូបភាពជាការរៀនតាមបណ្តុំ ដែលមានចំនួនតិចជាង ១៥ នាក់ និងឆ្លាស់វេន ដើម្បីងាយស្រួលក្នុងការបង្រៀន និងការគ្រប់គ្រង
- ចំពោះកម្រិតថ្នាក់ផ្សេងទៀត អាចរៀបចំការរៀនជាបណ្តុំមិនឱ្យលើសពី១៥នាក់ ទៅតាមស្ថានភាពជាក់ស្តែង ដោយអាចរៀបចំការរៀនតាមបណ្តុំនៅសាលារៀន និងបែងចែកវេន ឬបណ្តុំតាមចម្រុះថ្នាក់, ឬអាចរៀបចំនៅតាមផ្ទះ វត្តអារាម ឬកន្លែងសមស្រប
- រៀបចំចងក្រងបញ្ជីឈ្មោះសិស្សតាមបណ្តុំ និងតាមកម្រិតថ្នាក់នីមួយៗ។ ករណីបណ្តុំ មានសិស្សតិចពេក អាចផ្គួបកម្រិតថ្នាក់ចូលគ្នា ឬអាចផ្គួបលើសពី ២កម្រិតថ្នាក់។ ចំពោះការធ្វើតេស្តសិស្សប្រចាំខែ ឬឆមាស ករណីគ្រូបង្រៀនថ្នាក់គួបតាមបណ្តុំមិនអាចរៀបចំខ្លឹមសារតេស្ត ឬកែកិច្ចការបាន ត្រូវសហការគ្នាជាមួយគ្រូបង្រៀននៃកម្រិតថ្នាក់នោះ
- បែងចែកគ្រូបង្រៀនឱ្យទទួលខុសត្រូវតាមបណ្តុំ ឬតាមកម្រិតថ្នាក់នីមួយៗ (ករណីគ្រូបង្រៀនមិនអាចសម្របសម្រួលបាន ត្រូវរៀបចំសិស្សធំនៅបណ្តុំជាមួយគ្នា ឬមាតាបិតាជួយសិស្សតូចៗ)
- *ត្រូវបន្តអនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ*
  - បន្តការរៀនតាមបែបចម្រុះដូចជា រៀនតាមអនឡាញ, ចែកឯកសារ, និងរៀនផ្ទាល់ក្នុងថ្នាក់ ដោយត្រូវបែកចែកតាមវេន តាមក្រុម និងត្រូវពង្រឹងអនាម័យជាប្រចាំ
  - លើកទឹកចិត្តសិស្សដែលមានលទ្ធភាពរៀនតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យចេះប្រើប្រាស់វីដេអូនៃការបង្រៀន និងសន្លឹកកិច្ចការ ដែលផលិតដោយនាយកដ្ឋានជំនាញនៃក្រសួង និងដែលមានចែកចាយក្នុងបណ្តាញតេឡេក្រាម, វេបសាយ, ឬកម្មវិធីទូរសព្ទដៃ
  - បន្តអនុវត្តការបង្រៀនតាមបែបចម្រុះ និងតាមប្រព័ន្ធអឡិចត្រូនិក ដោយគ្រូបង្រៀនអាចបង្រៀន Live និងផ្តល់ឱកាសដល់សិស្សក្នុងការធ្វើស្វ័យសិក្សា ដោយប្រើប្រាស់សៀវភៅសិក្សាគោល និងតាមបែបអេឡិចត្រូនិក
  - អនុវត្តការធ្វើតេស្ត និងការវាយតម្លៃការសិក្សាសិស្ស ជាពិសេសថ្នាក់ទី៩ និងទី១២ ឱ្យបានគត់មត់ ក្រោមរូបភាពជាការប្រឡង ការធ្វើតេស្តដាក់ពិន្ទុប្រចាំខែ ត្រីមាស ប្រចាំឆ្នាំ
- *ការអនុវត្តកម្មវិធីសិក្សាបង្រួញ*
  - រៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ និងប្រចាំខែឡើងវិញ ដោយផ្តោតលើខ្លឹមសារមេរៀនសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការបន្តការសិក្សានៅថ្នាក់បន្តបន្ទាប់ទៀត
  - សង្ខេបខ្លឹមសារមេរៀនដោយផ្តោតលើបញ្ញត្តិ ដែលធ្វើឱ្យសិស្សងាយយល់ និងអាចយកទៅអនុវត្តបាន

- លើកទឹកចិត្តនិងជួយសិស្សឱ្យអនុវត្តលំហាត់ ឬធ្វើការហ្វឹកហាត់បន្ថែមនៅផ្ទះ
- មុខវិជ្ជាផ្សេងទៀតត្រូវព្យួរសិនដោយនឹងត្រូវរៀនបំពេញបន្ថែមនៅដើមឆ្នាំសិក្សាបន្ទាប់

**ទី៣- ការបង្រៀននិងរៀនពីចម្ងាយ តាមអនឡាញ ចំពោះភូមិសាស្ត្រដែលមានហានិភ័យខ្ពស់**

- បន្តការបង្រៀននិងរៀនតាមប្រព័ន្ធអេឡិចត្រូនិក និងចែកឯកសារ
- បន្តអនុវត្តការបង្រៀនតាមបែបចម្រុះ និងតាមប្រព័ន្ធអឡិចត្រូនិក ដោយគ្រូបង្រៀនអាចបង្រៀន Live និងផ្តល់ឱកាសដល់សិស្សក្នុងការធ្វើស្វ័យសិក្សា ដោយប្រើប្រាស់សៀវភៅសិក្សាគោល និងតាមបែបអេឡិចត្រូនិក
- អនុវត្តការធ្វើតេស្ត និងការវាយតម្លៃការសិក្សាសិស្ស ជាពិសេសថ្នាក់ទី៩ និងទី១២ ឱ្យបានគត់មត់ ក្រោមរូបភាពជាការប្រឡង ការធ្វើតេស្តដាក់ពិន្ទុប្រចាំខែ ត្រីមាស ប្រចាំឆ្នាំ
- ចំពោះភូមិសាស្ត្រដែលមានហានិភ័យខ្ពស់ អាចរៀបចំឱ្យមានការរៀនជាបណ្តុំនៅតាមផ្ទះ ការសិក្សាទៅតាមកន្លែងជាក់ស្តែង ដែលជ្រើសរើសដោយសហគមន៍ និងអាជ្ញាធរស្រុក និងការធ្វើជាបណ្តុំស្វ័យសិក្សាដោយសិស្សថ្នាក់ខ្ពស់ជួយសិស្សថ្នាក់ទាប ជាដើម
- ចំពោះភូមិសាស្ត្រដែលមានហានិភ័យខ្ពស់ ត្រូវតែមានការយល់ព្រមពីមាតាបិតា ឬអ្នកអាណាព្យាបាល និងទាមទារការចូលរួមពីមាតាបិតា ហើយត្រូវអនុវត្តតាមការរៀនតាមសន្លឹកកិច្ចការ
- ជំរុញមាតាបិតាក្នុងការជួយលើកទឹកចិត្ត និងបង្កលក្ខណៈដល់ការសិក្សាពីចម្ងាយ និងស្វ័យសិក្សារបស់សិស្ស ជាពិសេសសិស្សតូចៗ។

**ទី៤- ការពង្រឹងវិធានការការពារសុខភាពបុគ្គលិកអប់រំ អ្នកសិក្សា ជាពិសេសគ្រូបង្រៀនដែលមានអាយុលើសពី ៥០ឆ្នាំឡើងទៅ និងការបង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ៖**

- គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវពិនិត្យមើល, ចាត់វិធានការថែទាំ, លើកកម្ពស់អនាម័យសណ្តាប់ធ្នាប់នៅសាលារៀន ទោះបីជាគ្រឹះស្ថានសិក្សាមិនទាន់បើកដំណើរការឡើងវិញក៏ដោយ
- មិនអនុញ្ញាតឱ្យមានការលក់ដូរចំណី ឬអាហារ និងសកម្មភាពហាត់កីឡា នៅក្នុងគ្រឹះស្ថានសិក្សានោះទេ
- គ្រូបង្រៀនដែលមានអាយុលើសពី ៥០ឆ្នាំ ឡើងទៅ គួរតែបង្រៀនតាមអនឡាញ ឬចែកសន្លឹកកិច្ចការ។

**ទី៥- ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីមាតាបិតា និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្រេចនៅកម្រិតសាលារៀន ក្នុងការបើកឬផ្អាកដំណើរការសាលារៀន។**

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន លោកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ទ្វាទសីរោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  **"ដើម្បីជ្រាបជាព័ត៌មាន"**
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល